អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# រដ្ឋាភិបាលឈីលីផ្តល់ជំនួយថវិកាចំនួន ១០០០០ ដុល្លារដល់ អ.វ.ត.ក

រដ្ឋាភិបាលនៃប្រទេសឈីលី បានប្រកាសផ្តល់ជំនួយថវិកាចំនួន ១០ ០០០ ដុល្លារសហរដ្ឋអាម៉េរិកដល់ភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ ឈីលីគឺជាប្រទេសផ្តល់ជំនួយថ្មីមួយទៀតដល់ អ.វ.ត.ក ហើយការផ្តល់ជំនួយថវិកានេះបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការអំពាវនាវរបស់ឯកឧត្តម បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដល់រដ្ឋជាសមាជិកទាំងអស់ ជួយផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុជាបន្ទាន់ដល់ អ.វ.ត.ក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោកឃ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក. បានមានប្រសាសន៍ថា៖ “ជាមួយការប្រឈមមុខនឹងស្ថានភាពថវិកាដ៏លំបាកសម្រាប់ភាគីជាតិ យើងខ្ញុំមានក្តីសោមនស្សរីករាយ ស្វាគមន៍រដ្ឋាភិបាលឈីលីក្នុងនាមជាប្រទេសផ្តល់ជំនួយថ្មីរបស់ អ.វ.ត.ក។ នៅក្នុងនាម អ.វ.ត.ក យើងខ្ញុំសូមសម្តែងនូវអំណរគុណចំពោះប្រទេសឈីលីដែលបានផ្តល់វិភាគទាននេះ”។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោក **នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៥៥(០)១២ ៤៨៨ ១៥៦
ទូរស័ព្ទ៖ +៨៥៥(០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទ៖ +៨៥៥(០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក៖ olsenl@un.org